OAKLAND UNIFIED SCHOOL DISTRICT
Community Schools, Thriving Students

OFFICE OF THE SUPERINTENDENT
កាវិយាល័យនៃអគ្គនាយកនៃសង្កាត់សាលារៀនអូកឡិនដ៍

13 មីនា 2020

សូមជំរាបសួរប្រជាសហគមន៏នៃសង្កាត់សាលារៀនអូកឡិនដ៍,

នៅពេលដែលការព្រួយបារម្ភអំពីមេរោគកូរ៉ូណាបានកើនឡើង ក្រុមដឹកនាំរបស់នាងខ្ញុំ ព្រមទាំងនាងខ្ញុំ បានធ្វើការយ៉ាងជិតស្និទ្ធ ជាមួយនាយកដ្ឋានសុខភាពសាធារណ:ប្រចាំខោណធីអាឡាមីដា (ACPHD) និងការិយាល័យអប់រំប្រចាំខោណធីអាឡាមីដា (ACOE)។ ពួកគេបានរក្សាផ្តល់ព័ត៌មានថ្មីបំផុតឱ្យយើងខ្ញុំ នូវអនុសាសន៍ល្អបំផុត ពីរបៀបបំពេញការងារសាលារៀន នៅក្នុងកំឡុងពេល នៃភាពមិនទៀងទាត់នេះ។ នេះគឺជាមូលហេតុដែលយើងនៅតែសាលារៀនរបស់យើង មកទល់ថ្ងៃនេះ។

មកទល់នឹងម៉ោង 6:00 ល្ងាចក្នុងថ្ងៃនេះ **សាលារៀន និងមជ្ឈមណ្ឌលអភិវឌ្ឍកុមារទាំងអស់ នៅក្នុងសង្កាត់សាលារៀនអូកឡិនដ៍ នឹងត្រូវបានបិទ** យ៉ាងខ្លីបំផុត រហូតដល់ថ្ងៃអាទិត្យ ទី 5 ខែមេសា ដែលជាចុងបញ្ចប់នៃពេលសិស្សឈប់សម្រាកនៃរដូវផ្ការីក។ នេះមានន័យថា វានឹងមិនមានសាលារៀនថ្ងៃសៅរ៍ នៅថ្ងៃស្អែកនេះទេ ហើយនិងពុំមានកម្មវិធីបង្រៀនធម្មតា ចាប់ផ្តើមពីថ្ងៃច័ន្ទ ទី 16 ខែមីនា។ ការិយាល័យរបស់សង្កាត់ នឹងនៅតែបើក ប៉ុន្តែការចូលជួបជាសាធារណ:ដោយផ្ទាល់ នឹងត្រូវបានកំណត់។ បុគ្គលិកទាំងអស់នៃសង្កាត់សាលារៀនអូកឡិនដ៍ នឹងបន្តការងារ និងទទួលប្រាក់ខែនៅក្នុងរយ:ពេលនេះ ប៉ុន្តែការទទួលខុសត្រូវពិតប្រាកដ និងទីតាំងការដ្ឋាននានា អាចមានខុសៗគ្នា។ ក្នុងអំឡុងពេលនេះ សាលារៀននីមួយៗ នឹងទទួលបាននូវការលាងសំអាតយ៉ាងជ្រាស់ស្អាត។ ដោយសារតែការវិវត្តនៃធម្មជាតិនៃការរាតត្បាតមេរោគកូរ៉ូណានេះ យើងខ្ញុំសង្ឃឹមថា នឹងអាចបន្តបើកកម្មវិធីបង្រៀនសិស្សឡើងវិញ នៅថ្ងៃចន្ទ ទី 6 ខែមេសា ប៉ុន្តែយើងខ្ញុំនឹងបន្តវាយតម្លៃ ដើម្បីស្ថានភាព ដើម្បីកំណត់ពេលវេលាដែលល្អបំផុត ក្នុងការបើកសាលារៀនឡើងវិញ។

បន្ទាប់ពីការបានពិភាក្សា និងពិគ្រោះយោបល់យ៉ាងច្រើនជាមួយ ACPHD, ACOE, ថ្នាក់ដឹកនាំនៃទីក្រុង រួមទាំងជាមួយអភិបាលក្រុង Libby Schaaf និងដៃគូការងារ ព្រមទាំងអង្គការដៃគូរបស់យើងមក យើងខ្ញុំបានសម្រេចចិត្តថា វាគឺជាពេលត្រឹមត្រូវក្នុងការបិទសាលារៀនរបស់យើង។ វានឹងអនុញ្ញាតឱ្យសិស្ស បុគ្គលិកសាលារៀន និងក្រុមគ្រួសារទាំងអស់ ធ្វើអ្វីៗដែលពួកគេត្រូវធ្វើ ដើម្បីរក្សាខ្លួនឱ្យមានសុខភាពល្អ និងជួយទប់ស្កាត់ការរីករាលដាលនៃមេរោគកូរ៉ូណានេះ។ នេះគឺជាដំណោះស្រាយដែលមិនល្អឥតខ្ចោះនោះទេ ព្រោះអ្នកជំនាញ ACPHD ប្រាប់យើងខ្ញុំមកថា បើកុមារមិនស្នាក់នៅក្នុងផ្ទះរបស់ពួកគេ ដើម្បីនៅឱ្យឆ្ងាយពីមនុស្សផ្សេងទៀតសម្រាប់រយ:ពេលនៃការបិទសាលាទេនោះ ពួកគេនៅតែអាចឆ្លងមេរោគនេះ

ការបិទសាលារៀន គឺប៉ះពាល់ក្រុមគ្រួសាររបស់យើងច្រើនណាស់ ដែលពឹងផ្អែកលើសាលារៀននានាក្នុងការផ្តល់ទីកន្លែងមានសុវត្ថិភាពសំរាប់កូនៗរបស់ពួកគេ សំរាប់ម្ហូបអាហារ និងសំរាប់សេវាកម្មផ្សេងទៀតជាច្រើន។ ទីសាលារៀននានា នឹងបន្តរៀបចំផែនការបន្តបង្រៀនសិស្ស ដោយមានសាលារៀននីមួយៗ ត្រៀមផ្តល់នូវកិច្ចការសិក្សាដល់សិស្ស។ ទោះយ៉ាងណាក៏ដោយ កិច្ចខិតខំប្រឹងប្រែងនេះ មិនត្រូវបានរចនាឡើង ដើម្បីជំនួសគុណតម្លៃនៃការបង្រៀននៅសាលារៀន ដោយមានគ្រូបង្រៀននោះទេ។ ផែនការនៃសាលារៀននីមួយៗ នឹងត្រូវបានបង្ហោះជូននៅលើគេហទំព័ររបស់យើង។ យើងខ្ញុំរំពឹងថាផែនការទាំងអស់ នឹងត្រូវបានបង្ហោះជូននៅថ្ងៃអង្គារ៍ ឬថ្ងៃពុធ នាសប្តាហ៍ក្រោយ។

ក្នុងអំឡុងពេលបិទសាលារៀន នាយកដ្ឋានបំរើសេវាអាហាររូបត្ថម្ភរបស់យើង នឹងបើកបំរើនៅតាមទីសាលារៀនចំនួនដប់ពីរកន្លែង នៅទូទាំងទីក្រុង ជាទីដែលអាចឈោងចូលយកអាហារពេលព្រឹក និងអាហារថ្ងៃត្រង់ កូនសិស្សរបស់យើង។ ទីសាលារៀននានា ដែលមានចុះជូនខាងក្រោមនេះ នឹងត្រូវបានបើក តាមពេលវេលា ហើយកុមារអាចចូលមកយកម្ហូបអាហារទុកបានជាច្រើនថ្ងៃ ដើម្បីទទួលនៅឯផ្ទះ។

- ថ្ងៃច័ន្ទ៖ ម៉ោង 8:00-12:00 (អាហារពេលព្រឹក 3 ពេល / អាហារថ្ងៃត្រង់ 3 ពេល សំរាប់កូនសិស្សម្នាក់ៗ)
- ថ្ងៃព្រហស្បត្តិ៍៖ ម៉ោង 8:00-12:00 (អាហារពេលព្រឹក 2 ពេល / អាហារថ្ងៃត្រង់ 2 ពេល សំរាប់កូនសិស្សម្នាក់ៗ)

មានផ្តល់អាហារជូនដល់កុមារដែលមានវ័យ 18 ឆ្នាំ។
សូមយកថង់មកដាក់គ្រឿងធ្វើម្ហូប ឬប្រដាប់ដាក់ទឹកដើម្បីយកម្ហូបអាហារទៅផ្ទះសំរាប់សប្តាហ៍។

- ទីក្រុងអូកឡិនដ៍ប៉ែកខាងជើង និងខាងលិច៖ សាលា Sankofa Elementary, West Oakland Middle School និងសាលា Hoover Elementary
- ទីក្រុងអូកឡិនដ៍ប៉ែកកណ្តាល៖ សាលា Oakland High School និង Garfield Elementary
- ទីក្រុងអូកឡិនដ៍ប៉ែកខាងកើត៖ សាលាBret Harte Middle School, Life Academy/United for Success, Coliseum College Preparatory Academy, Madison Park Upper, Fremont High School, Castlemont High School និងសាលា Elmhurst United Middle School

យើងខ្ញុំដឹងថាពេលនេះ នឹងមានការលំបាកសម្រាប់ក្រុមគ្រួសារជាច្រើន នៃក្រុមគ្រួសាររបស់យើង ហើយយើងសូមអរគុណចំពោះការអត់ធ្មត់ និងការព្យាយាមរបស់អ្នក។ យើងខ្ញុំនឹងទំនាក់ទំនងគ្នាជាញឹកញាប់តាមរយ:អ៊ីម៉ែល, ទូរស័ព្ទដោយស្វ័យប្រវត្ត, ប្រព័ន្ធផ្សព្វផ្សាយសង្គម និងគេហទំព័ររបស់យើង (www.ousd.org/coronavirus) អំពីការប្រែប្រួលកាល:ទេស:, ការអាចរកបាននូវម្ហូបអាហារ និងការសិកស្សា។ យើងនឹងធ្វើបានល្អបំផុតដាច់ខាតរបស់យើងដើម្បីរក្សាអ្នករាល់គ្នាបានជូនដំណឹងនិងមានសុវត្ថិភាពក្នុងអំឡុងគ្រាមានការលំបាកទាំងនេះ។ក្នុងពេលនេះ, សូមថែរក្សាខ្លួនអ្នក, ក្រុមគ្រួសារនិងសហគមន៍របស់យើង។

យើងខ្ញុំនឹងខិតខំឱ្យអស់ពីសមត្ថភាព ដើម្បីផ្តល់ព័ត៌មានដល់មនុស្សគ្រប់គ្នា ក្នុងគ្រាលំបាកទាំងនេះ។ ក្នុងពេលនេះ សូមថែរក្សាខ្លួនអ្នក ក្រុមគ្រួសារ និងសហគមន៍របស់យើង។ សូមអរគុណ ចំពោះភាពជាដៃគូរបស់អ្នក នៅពេល ដែលយើង សហការរួមគ្នា ក្នុងគ្រាលំបាកទាំងនេះ។

ដោយក្តីគោរពស្មោះពីនាងខ្ញុំ,

Dr. Kyla Johnson-Trammell
អគ្គនាយកនៃសង្កាត់សាលារៀនអូកឡិនដ៍

1000 Broadway, Suite 300, Oakland, CA 94607
510.879-8200 ph
www.ousd.org